


# បេសកកម្មនិងគុណតម្លៃរបស់យើង

## ចក្ខុវិស័យរបស់យើងគឺផ្តល់ឱ្យសិស្សានុសិស្សទាំងអស់នូវការអប់រំសម្រាប់ជីវិត។ យើងពង្រឹងនូវគុណសម្បត្តិផ្ទាល់ខ្លួនដែលចាំបាច់សម្រាប់ការសិក្សារៀនសូត្រពេញមួយជីវិត។

### បេសកកម្មរបស់យើង

តាមរយៈការជំរុញនិងយកចិត្តទុកដាក់ពីសំណាកគ្រូបង្រៀន ព្រមជាមួយនឹងបរិយាកាសសហសិក្សាប្រកបដោយសុវត្ថិភាពទាំងផ្លូវកាយនិងផ្លូវចិត្ត មហាវិទ្យាល័យ ស៊ែន លេអូណាដស៍ ផ្តល់នូវការអប់រំតាមគំរូបែបថ្មីមួយ សម្រាប់សិស្សានុសិស្សរបស់ខ្លួនដែលពោរពេញទៅដោយប្រពៃណីនៃកេរ្តិ៍តេករបស់ខ្លួន។

### គុណតម្លៃរបស់យើង

ការសិក្សារៀនសូត្រពេញមួយជីវិត
យើងផ្តល់តម្លៃនិងអភិវឌ្ឍគុណសម្បត្តិនិងជំនាញផ្ទាល់ខ្លួនសំខាន់ៗ សម្រាប់ការសិក្សារៀនសូត្រពេញមួយជីវិត រួមមានភាពជឿជាក់លើខ្លួនឯង ភាពសុចរិត ភាពរឹងមាំ និងភាពច្នៃប្រឌិត។ ការអប់រំរបស់ ស៊ែន លេអូណាដស៍ ផ្តល់ឱ្យសិស្សានុសិស្សនូវការត្រៀមលក្ខណៈរួចជាស្រេចក្នុងការចាប់យកកន្លែងនៅក្នុងពិភពលោក និងរួមចំណែកប្រកបដោយអត្ថន័យដល់សង្គមជាតិ។

ធនធានមនុស្ស
យុវជនរបស់យើងត្រូវបានលើកទឹកចិត្តឱ្យប្រកាន់យកនូវភាពចម្រុះនិងបុគ្គលភាព ក៏ដូចជាទំនួលខុសត្រូវជារួមផងដែរ។

ភាពជាដៃគូ
យើងចាត់ទុកការអប់រំគឺជាភាពជាដៃគូរវាងសិស្សានុសិស្ស គ្រូបង្រៀន និងមាតាបិតា ដែលម្នាក់ៗមានតួនាទីនិងទំនួលខុសត្រូវដាច់ដោយឡែកពីគ្នា។

គ្រូបង្រៀន
គ្រូបង្រៀនរបស់យើងប្តេជ្ញាបន្តអភិវឌ្ឍខ្លួននិងវិជ្ជាជីវៈ និងប្រកាន់យកនូវការអប់រំប្រកបដោយភាពច្នៃប្រឌិត។ ពួកគេមានសមត្ថភាពយ៉ាងពេញលេញក្នុងការសម្របខ្លួនទៅតាមការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃការអប់រំ។

សហគមន៍
សិស្សានុសិស្សមានការយល់ដឹងពីតម្រូវការរបស់សហគមន៍ខាងក្រៅ ហើយក៏កំពុងរៀនសូត្រដើម្បីចូលរួមនៅក្នុងពិភពលោកខាងក្រៅសហគមន៍នៃមហាវិទ្យាល័យផងដែរ។

បរិស្ថាន
យើងប្តេជ្ញាការពារបរិស្ថាន ក៏ដូចជាជួយដោះស្រាយបញ្ហាប្រឈមដែលមនុស្សជំនាន់ក្រោយនឹងត្រូវប្រឈមមុខ។

ភាពចម្រុះគ្នា
យើងស្វាគមន៍ទទួលនូវគ្រប់វប្បធម៌ទាំងអស់ និងសាទរនូវភាពចម្រុះគ្នា។ សិស្សានុសិស្សរបស់យើងត្រូវបានលើកទឹកចិត្តឱ្យប្រាស្រ័យទាក់ទងជាមួយមនុស្សនិងវប្បធម៌ដែលស្ថិតនៅខាងក្រៅពិភពរបស់ពួកគេ។